# ក្របខណ្ឌភាពជាដៃគូសម្រាប់ប្រទេសកម្ពុជា (CPF) ២០១៩-២០២៣

*សេចក្តីសង្ខេបនៃការពិភាក្សាពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ*

ភ្នំពេញ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩

អ្នកចូលរួម៖ មានតំណាងចំនួន ៥៧រូប មកពីរដ្ឋបាលថ្នាក់ក្រោមជាតិ (ថ្នាក់ខេត្តចំនួន១២នាក់ ថ្នាក់ស្រុក ១៥នាក់ ថ្នាក់ឃុំ ៣០នាក់)។

សេចក្តីផ្តើម៖ ធនាគារពិភពលោកបើកកិច្ចពិគ្រោះយោបល់នេះដោយធ្វើការរៀបរាប់សង្ខេបពីអំពីបរិបទរបស់ប្រទេស និងអាទិភាពនានាក្នុងកិច្ចការអភិវឌ្ឍន៍ ដូចត្រូវបានរកឃើញតាមរយៈការវិនិច្ឆ័យស្ថានភាពប្រទេសដែលមានលក្ខណៈជាប្រព័ន្ធ (SCD) ព្រមទាំងសំណើវិស័យត្រូវផ្តោតយកចិត្តទុកដាក់សម្រាប់ក្របខណ្ឌភាពជាដៃគូសម្រាប់ប្រទេសកម្ពុជា (CPF) ដែលស្របតាមអាទិភាពរបស់យុទ្ធសាស្រ្តចតុកោណនៃរាជរដ្ឋាភិបាលកម្ពុជា។ បណ្តាវិស័យត្រូវផ្តោតយកចិត្តទុកដាក់ក្នុងក្របខណ្ឌភាពជាដៃគូសម្រាប់ប្រទេសកម្ពុជា (CPF) រួមមាន៖ ១) លើកកម្ពស់ប្រសិទ្ធផលរបស់រដ្ឋ និងជំរុញការអភិវឌ្ឍវិស័យឯកជន, ២) ជំរុញការអភិវឌ្ឍមនុស្ស, ៣) កែលម្អវិស័យកសិកម្ម និងពង្រឹងការប្រើប្រាស់ប្រកបដោយចីរភាពនូវធនធានធម្មជាតិឱ្យកាន់តែប្រសើរ និងមូលបទអន្តរវិស័យស្តីពីការពង្រឹងអភិបាលកិច្ច ស្ថាប័ន និងការចូលពាក់ព័ន្ធរបស់ពលរដ្ឋ។ បន្ថែមលើមាគ៌ាដែលត្រូវបានគ្រួសត្រាយដោយការវិនិច្ឆ័យស្ថានភាពប្រទេសមានលក្ខណៈជាប្រព័ន្ធ (SCD) និងយុទ្ធសាស្រ្តរបស់រាជរដ្ឋាភិបាល ក្របខណ្ឌភាពជាដៃគូសម្រាប់ប្រទេសកម្ពុជា មានគោលដៅពិចារណាមើលអំពីឧត្តមភាពប្រៀបធៀបនៃវិស័យគម្រោងអនុវត្តនានារបស់ក្រុមធនាគារពិភពលោក។ នៅក្នុងកិច្ចពិគ្រោះយោបល់នេះ អ្នកចូលរួមត្រូវបានបែងចែកជាក្រុមៗឱ្យធ្វើការជជែកបំផុសគំនិត កត់ត្រាចម្លើយតបទៅនឹងសំណួរពិភាក្សារបស់ធនាគារពិភពលោក ហើយបន្ទាប់មកធ្វើបទបង្ហាញអំពីការសន្និដ្ឋានតាមក្រុមរៀងៗខ្លួន។

បញ្ហាធំៗដែលត្រូវបានលើកឡើងនៅក្នុងកិច្ចពិភាក្សាមាន៖ ការកសាងសមត្ថភាព ការអភិវឌ្ឍជំនាញ ពង្រឹងការងារផ្តល់សេវាកម្ម ការគ្រប់គ្រងធនធានធម្មជាតិ និងការគ្រប់គ្រងទឹក ហេដ្ឋារចនាសម្ព័ន្ធ កសិកម្ម។

| វិស័យដែលត្រូវបានលើកយកមក | ចំណុចគោលសំខាន់ៗដែលបានលើកឡើង |
| --- | --- |

| ពិភាក្សា | |
|---|---|
| **តើអ្វីខ្លះទៅជាបញ្ហាប្រឈមនិងភាពចាំបាច់បន្ទាន់ជាងគេនៅក្នុងការអភិវឌ្ឍរបស់ប្រទេសកម្ពុជា?** | • ការគ្រប់គ្រងធនធានធម្មជាតិគឺជាបញ្ហាសំខាន់មួយដែលមានឥទ្ធិពលទៅលើកំណើនសេដ្ឋកិច្ច។ បញ្ហាជាច្រើនមាននៅក្នុងការប្រើប្រាស់ធនធាន ការចោលកាកសំណល់មិនត្រឹមត្រូវ និងការការពារបរិស្ថាន។ ទាំងតំបន់ទីក្រុងនិងទាំងតំបន់ជនបទ សុទ្ធតែមានភាពចាំបាច់ត្រូវមានការប្រមូលកាកសំណល់ ការចោល ឬការធ្វើប្រព្រឹត្តិកម្មកាកសំណល់ និងការធ្វើប្រព្រឹត្តិកម្មទឹកសម្អុយឱ្យបានល្អជាងបច្ចុប្បន្ន។ ការអប់រំស្តីពីការបំពុល និងបញ្ហាផ្សេងទៀត គឺមានសារៈសំខាន់។ បញ្ហាធនធានធម្មជាតិក៏មានផលប៉ះពាល់ដល់វិស័យកសិកម្មដែរ។ ការអនុវត្តច្បាប់ការពារធនធានធម្មជាតិក៏មិនទាន់មានប្រសិទ្ធភាពដែរ ក្នុងការអនុវត្តតាមគោលនយោបាយ។<br>• បញ្ហាកម្មករខ្វះសមត្ថភាព និងបញ្ហាគម្លាតយេនឌ័រ ឃើញថាមានវឌ្ឍនភាពប្រសើរខ្លះមែន ប៉ុន្តែវានៅតែជាបញ្ហាដដែល។<br>• សហគ្រាសខ្នាតតូចនិងមធ្យមនៅតែមិនទាន់មានភាពរឹងមាំនៅឡើយទេនៅកម្ពុជា។ ពួកគេគួរតែមានការគាំទ្របន្ថែមទៀត សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនាពេលអនាគត។<br>• ធនធានមនុស្សរបស់ប្រទេសកម្ពុជានៅមានការអភិវឌ្ឍទាប។ ការអប់រំត្រូវតែផ្តោតលើជំនាញចាំបាច់សម្រាប់វិស័យឧស្សាហកម្មនាពេលអនាគតរបស់ប្រទេស។<br>• ការអប់រំកុមារតូចក៏ជាបញ្ហាមួយដែរ។ នៅតំបន់ជនបទបញ្ហាអាចមកពីគ្មានកន្លែងគ្រប់គ្រាន់ ឬវាអាចមកពីមានការលំបាកបន្តិច ដោយសារហេតុផលផ្សេងៗ នៅក្នុងការបញ្ចុះបញ្ចូលមាតាបិតាឱ្យបញ្ជូនកូនៗរបស់ខ្លួន ទៅឱ្យទទួលការអប់រំនៅវ័យក្មេង។<br>• ប្រទេសកម្ពុជាមានផលិតភាពទាប និងសមត្ថភាពទាប ជាងបណ្តាប្រទេសដទៃទៀតនៅក្នុងតំបន់។ ដំណើរការកែច្នៃផលិតផលគួរតែមានការកែលម្អឱ្យប្រសើរឡើង។ តំបន់មួយចំនួនខ្វះប្រព័ន្ធធារាសាស្ត្រ ឬទឹកគ្រប់គ្រាន់ ដើម្បីអនុវត្តបច្ចេកទេសកសិកម្មទំនើប រឺសម្រាប់ធ្វើការដាំដុះនៅក្នុងរដូវប្រាំង។<br>• ផ្នែកសាធារណៈការនៅតាមជនបទនៅមានលក្ខណៈអន់ថយ ហើយទឹកជំនន់បានធ្វើឱ្យខូចខាតផ្លូវ និងបង្កការលំបាកចេញចូលតំបន់មួយចំនួន។ ជាទូទៅការបំពេញគម្លាតហេដ្ឋារចនាសម្ព័ន្ធគួរតែជាអាទិភាពមួយ - ក្នុងនោះមានផ្លូវថ្នល់ បណ្តាញគមនាគមន៍ សាលារៀន និងប្រព័ន្ធទឹកជាដើម។<br>• មណ្ឌលផ្តល់សេវាសុខភាពនៅមិនទាន់មាននៅឡើយនៅតាមតំបន់មួយចំនួន ហើយនៅតាមតំបន់ដទៃទៀតដែលមាននោះ មណ្ឌលសុខភាពនៅខ្វះសមត្ថភាពនិងការបំពាក់បរិក្ខារ ដូច្នេះប្រជាជនសុខចិត្តចំណាយធ្វើដំណើរទៅកាន់ប្រទេសផ្សេងទៀតដើម្បីរកសេវាថែទាំសុខភាពវិញ។<br>• ការបង្កើនលទ្ធភាពទទួលបានហិរញ្ញវត្ថុ និងលើកទឹកចិត្តដល់ការអភិវឌ្ឍវិស័យឯកជនមានសារៈសំខាន់។<br>• ទម្លាប់អនុវត្តន៍ក្នុងការផ្តល់ឥណទានដោយគ្មានទំនួលខុសត្រូវ បានបង្កើតឱ្យមានស្ថានភាពជំពាក់បំណុលនៅក្នុងសហគមន៍ជាច្រើន ដែលជា |

| | |
|---|---|
| | កត្តាហានិភ័យមួយនាំឱ្យមានការធ្វើចំណាកស្រុក។ |
| **តើមានអ្វីខ្លះជាវិស័យអាទិភាពសម្រាប់ក្រុមធនាគារពិភពលោកបន្តជួយឧបត្ថម្ភនៅក្នុងអំឡុងពេល៥ឆ្នាំខាងមុខ? មានអ្វីខ្លះដែលក្រុមធនាគារពិភពលោកគួរបន្តសកម្មភាពជួយបន្ថែមទៀត ឬបន្ថយសកម្មភាពវិញ?** | *ការអភិវឌ្ឍមនុស្ស*<br>• អ្នកចូលរួមកិច្ចពិគ្រោះយោបល់បានសរសើរចំពោះការចូលពាក់ព័ន្ធនាពេលបច្ចុប្បន្នរបស់ធនាគារពិភពលោកក្នុងវិស័យអប់រំ សុខាភិបាល និងការអភិវឌ្ឍជំនាញ ហើយបានជំរុញឱ្យធនាគារបន្តគាំទ្រដល់វិស័យសំខាន់ៗទាំងនេះទៀត។<br>• ធនាគារពិភពលោកគួរតែបន្តគាំទ្រដល់ការធ្វើឱ្យមានគុណភាពកាន់តែប្រសើរឡើងនៅក្នុងសេវាថែទាំសុខភាព និងមូលនិធិសមធម៌សុខាភិបាល សំរាប់ជនក្រីក្រ។ ការកែលម្អសេវាអាចជួយកសាងទំនុកចិត្តនៅក្នុងប្រព័ន្ធសុខាភិបាលក្នុងមូលដ្ឋាន។ បុគ្គលិកសុខាភិបាលក៏ចាំបាច់ត្រូវមានការបណ្តុះបណ្តាលបន្ថែមទៀតផងដែរ។<br>• នៅក្នុងវិស័យអប់រំ ធនាគារពិភពលោកគួរលើកទឹកចិត្តឱ្យមានការអប់រំផ្នែកវិទ្យាសាស្ត្រប្រសើរឡើងនៅតំបន់ជនបទ មិនត្រឹមតែនៅទីក្រុងប៉ុណ្ណោះទេ។ ការបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងវិស័យកសិកម្ម និងពាណិជ្ជកម្ម មានសារៈសំខាន់ណាស់ក្នុងការអភិវឌ្ឍជំនាញរបស់កម្មករ។ ធនាគារពិភពលោកគួរតែពិចារណាគាំទ្រមជ្ឈមណ្ឌលសិក្សាសហគមន៍សម្រាប់ការបណ្តុះបណ្តាល។<br>• ធនាគារពិភពលោកគួរពិចារណាធ្វើភាពជាដៃគូ និងធ្វើការពិគ្រោះយោបល់បន្ថែមជាមួយសមាគមអ្នកក្រីក្រ ពាក់ព័ន្ធនឹងការបង្កើតការងារធ្វើ។<br>• ការគាំទ្រដល់ការពង្រឹងសហគ្រាសខ្នាតតូចនិងមធ្យមគឺមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច។ ការគាំទ្របែបនេះគួរដើរទន្ទឹមគ្នាជាមួយនឹងការអភិវឌ្ឍជំនាញរបស់បុគ្គលិក និងកម្មវិធីសិក្សាទូទៅ ក៏ដូចជាការកែលម្អបច្ចេកវិទ្យាផងដែរ។<br><br>*ការអភិវឌ្ឍជនបទ និងហេដ្ឋារចនាសម្ព័ន្ធ*<br>• ធនាគារពិភពលោកគួរវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធនៅតាមខេត្ត (ឧទាហរណ៍ប្រព័ន្ធទឹក និងអនាម័យ) ដើម្បីកាត់បន្ថយគម្លាតហេដ្ឋារចនាសម្ព័ន្ធ។<br>• ជួយដល់សមាគមអ្នកក្រីក្រ និងពង្រីកគម្រោងទ្រទ្រង់ជីវភាព។<br><br>*បរិស្ថាន និងកសិកម្ម*<br>• ការគាំទ្រដែលធនាគារពិភពលោកបានគ្រោងទុកដល់វិស័យកសិកម្មត្រូវទទួលបានការសរសើរពីសំណាក់អ្នកចូលរួម។ ប៉ុន្តែ ធនាគារគួរគាំទ្រវិស័យនេះតាមរយៈការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធធារាសាស្ត្រ ដើម្បីសម្រួលឱ្យមានការដាំដុះពេញមួយឆ្នាំ ដល់ការធ្វើពិពិធកម្ម ការកែលម្អបច្ចេកវិជ្ជា និងការធ្វើពាណិជ្ជកម្មកសិផល។ |

| | |
|---|---|
| | • អេកូទេសចរណ៍គឺជាឱកាសមួយដែលធនាគារពិភពលោកគួរគាំទ្រ ដើម្បីជួយសហគមន៍មូលដ្ឋានក្នុងការរកប្រាក់ចំណូល ហើយតាមរយៈនេះវាជួយធានាថាធនធានធម្មជាតិត្រូវបានការពារផងដែរ។<br>• ការគ្រប់គ្រងចំហានិភ័យគ្រោះមហន្តរាយ គឺជាវិស័យមួយដែលត្រូវការការយកចិត្តទុកដាក់បន្ថែមទៀត ជាពិសេសការជន់លិច និងគ្រោះរាំងស្ងួត ដើម្បីកាត់បន្ថយភាពក្រីក្រដែលបណ្តាលមកពីភាពងាយរងគ្រោះរបស់ពលរដ្ឋ។<br>• ធនាគារពិភពលោកគួរតែគាំទ្រការកាត់បន្ថយការបំពុល។ ក្នុងនេះមានការតម្រូវឱ្យមានការកែលម្អការចោលកាកសំណល់ និងការធ្វើប្រព្រឹត្តិកម្មកាកសំណល់ ការលុបបំបាត់ការចោលកាកសំណល់ជាសាធារណៈ និងកាត់បន្ថយការប្រើប្រាស់ប្លាស្ទិច។ |
| **តើមានអ្វីខ្លះដែលអាចជាបញ្ហាប្រឈមគួរឱ្យកត់សម្គាល់សម្រាប់ការអនុវត្ត ហើយថាតើបញ្ហាប្រឈមទាំងនោះអាចត្រូវបានកាត់បន្ថយតាមរបៀបណាខ្លះ?** | • កង្វះសមត្ថភាពរបស់ភ្នាក់ងារអនុវត្តអាចជាបញ្ហាប្រឈមមួយ ដែលគួរមានការបណ្តុះបណ្តាលរយៈពេលខ្លីនិងមធ្យមថែមទៀត។ កំណែទម្រង់វិស័យទូទៅបន្ថែមទៀត និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គួរតែត្រូវបានធ្វើឱ្យប្រសើរឡើងផងដែរ ដើម្បីធានាថាការផ្តល់សេវាមានទាំងប្រសិទ្ធភាព និងប្រសិទ្ធផល។<br>• ស្ថានភាពនយោបាយ និងសេដ្ឋកិច្ចសកល ក៏ដាក់សម្ពាធនិងហានិភ័យពីខាងក្រៅមើកលើគម្រោងនានានៅក្នុងប្រទេសកម្ពុជាដែរ។<br>• គម្រោងគ្មានប្រសិទ្ធិភាពទេ បើវាគ្មានការជឿជាក់ និងការចូលរួមពីសំណាក់សហគមន៍មូលដ្ឋាន។ ការងារគួរតែត្រូវធ្វើបន្ថែមដើម្បីលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីគម្រោងនានានៅក្នុងតំបន់របស់ពួកគេ និងធានាថាពួកគេបានចូលរួមផងដែរ។ គម្រោងគួរតែមានការសម្របសម្រួលឱ្យបានល្អប្រសើរជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីលើកទឹកចិត្តដល់សមាជិកសហគមន៍ឱ្យចូលរួម។<br>• កម្រិតទាបនៃភាពទន់ខ្សោយក្នុងការរឹតបន្តឹងការអនុវត្តគោលនយោបាយ និងច្បាប់ដែលមានស្រាប់ទាក់ទិនទៅនឹងការប្រើប្រាស់ធនធានធម្មជាតិ នៅតែជាបញ្ហាប្រឈម។<br>• វាមានការលំបាកក្នុងការបន្តគម្រោងបន្ទាប់ពីវាត្រូវបានបញ្ចប់។ ការបណ្តុះបណ្តាលបន្ថែមទៀតដល់សមាជិកសហគមន៍ និងរដ្ឋបាលមូលដ្ឋានគួរតែត្រូវបានធ្វើដើម្បីធានាឱ្យមាននិរន្តរភាពក្រោយគម្រោងចប់។<br>• ការធ្វើចំណាកស្រុកកំពុងតែធ្វើឱ្យមូលដ្ឋានបាត់បង់ចំណេះដឹង និងជំនាញក្នុងស្រុក បន្តិចម្តងៗ។ |
| **អត្ថាធិប្បាយផ្សេងៗទៀត** | • អ្នកចូលរួមជាច្រើនបានសម្តែងការពេញចិត្តជាទូទៅចំពោះភាពជាដៃគូរបស់ធនាគារពិភពលោក ហើយបានស្នើសុំឱ្យមានការគាំទ្រគម្រោងដែលអាចមាននិរន្តរភាព ទោះបីជាមានការគាំទ្រពីម្ចាស់ជំនួយត្រូវបានបញ្ចប់ក៏ដោយ។ ពួកគេក៏បានលើកឡើងផងដែរអំពីភាពលំបាកនៃការជ្រើសរើសតែវិស័យសំខាន់មួយចំនួនសម្រាប់ផ្តោតសកម្មភាពលើ នៅពេលមានតម្រូវការខុសៗគ្នាជាច្រើន ជាពិសេសនៅតាមជនបទទូទាំងប្រទេស។ |